# ការទទួលទីបន្ទាល់អំពីព្រះជាព្រះវរបិតា ព្រះរាជបុត្រា គឺព្រះយេស៊ូវគ្រីស្ទ និងព្រះវិញ្ញាណបរិសុទ្ធ

អែលឌើរ រ៉ូប៊ឺត ឌី ហេល
នៃក្រុមនៃពួកសាវកដប់ពីរនាក់

*អ្វីដែលបានប្រាប់មកខ្ញុំ... អាចត្រូវបានប្រាប់ដល់អ្នករាល់គ្នា ដោយព្រះវិញ្ញាណបរិសុទ្ធ... ស្របតាមការគោរពប្រណិបត្តិ និងបំណងប្រាថ្នារបស់អ្នក ។*

ខ្ញុំ ក៏ដូចជាអ្នករាល់គ្នា មានអំណរគុណនៅក្នុងការប្រជុំដ៏ឧឡារិកនេះ ។ ប៉ុន្តែខ្ញុំគិតថា ខ្ញុំអាចផ្តល់ចំនុចមួយនៃគោលលទ្ធិ និងជំនួយ ។ នៅពេលយើងលើកដៃឡើងជាកែងនៅក្នុងការប្រជុំដ៏ឧឡារិកនេះ យើងមិនត្រឹមតែបោះឆ្នោតថាយើងផ្តល់ឱ្យនូវខ្លួនយើងនៃការប្តេជ្ញាចិត្តជាឯកជន និងផ្ទាល់ខ្លួនប៉ុណ្ណោះទេ តែជាសេចក្តីសញ្ញាមួយ ដើម្បីគាំទ្រ និងលើកដំកើងច្បាប់ពិធីបរិសុទ្ធ បទបញ្ញត្តិ និងព្យាការីរបស់ព្រះ ប្រធានថូម៉ាស អេស ម៉នសុន ។ ខ្ញុំមានក្តីអំណរណាស់ ដែលបានចូលរួមជាមួយអ្នករាល់គ្នា ហើយលើកដៃស្តាំរបស់ខ្ញុំជាកែង ។

បងប្អូនប្រុសស្រីរបស់ខ្ញុំ អស់ជាច្រើនខែកន្លងទៅ ខ្ញុំបានទទួលបទពិសោធន៍ដ៏រាបសារមួយ ដែលបានផ្តល់ឱ្យខ្ញុំនូវឱកាសដើម្បីនឹកគិតឡើងវិញដោយដឹងគុណ ចំពោះអំណោយទាននៃជីវិត ។ អំឡុងពេលនៃបទពិសោធន៍នេះ ខ្ញុំបានគិតពិចារណាជាបន្តបន្ទាប់អំពីទីបន្ទាល់របស់ខ្ញុំអំពីព្រះ ជាព្រះវរបិតាសួគ៌ដ៏នៅអស់កល្បជានិច្ចរបស់យើង និងព្រះរាជបុត្រាច្បងបង្អស់របស់ទ្រង់ ដែលជាព្រះអង្គសង្គ្រោះ និងជាព្រះប្រោសលោះរបស់យើង គឺព្រះយេស៊ូវគ្រីស្ទ និងរបៀបដែលខ្ញុំបានទទួលនូវទីបន្ទាល់របស់ខ្ញុំអំពីព្រះវរបិតា និងព្រះរាជបុត្រានោះ ។

មនុស្សទាំងអស់នៅលើពិភពលោក គ្រប់សាសនា និងជំនឿផ្សេងៗ បានស្រាវជ្រាវ និងពុះពារចង់ដឹង តើព្រះជានរណា? តើទំនាក់ទំនងរបស់ទ្រង់នឹងព្រះយេស៊ូវគ្រីស្ទយ៉ាងណាខ្លះ? ហើយ តើទំនាក់ទំនងរបស់យើងជាមួយនឹងពួកគេយ៉ាងណាដែរ?

ខ្ញុំដឹងដោយពិតថាព្រះវរបិតាសួគ៌របស់យើង និងព្រះយេស៊ូវគ្រីស្ទ នៅមានព្រះជន្មរស់ ។ ដង្វាយធួនគឺជាការពិត ។ ព្រះជាព្រះវរបិតា និងព្រះយេស៊ូវគ្រីស្ទ មានតួអង្គអមតៈផ្សេងដាច់ដោយឡែកពីគ្នា ។ ពួកទ្រង់ស្គាល់យើងម្នាក់ៗ ហើយស្តាប់ឮ និងឆ្លើយតបចំពោះការអធិស្ឋានដោយស្មោះស្ម័គ្ររបស់យើង ។ ព្រះអង្គសង្គ្រោះបានធ្វើទីបន្ទាល់ចំពោះប្រជាជននៃពិភពលោកថ្មីថា: "ហើយយើងធ្វើបន្ទាល់អំពីព្រះវរបិតា ហើយព្រះវរបិតាធ្វើបន្ទាល់អំពីយើង ហើយព្រះវិញ្ញាណបរិសុទ្ធធ្វើបន្ទាល់អំពីព្រះវរបិតា និងអំពីយើង" ។1 ព្រះវិញ្ញាណបរិសុទ្ធបានធ្វើបន្ទាល់ចំពោះខ្ញុំនូវរឿងទាំងនេះថាជាការពិត ។

ខ្ញុំចាប់ផ្តើមទទួលទីបន្ទាល់របស់ខ្ញុំកាលពីយុវវ័យ នៅពេលខ្ញុំនឹកគិតអំពីសេចក្តីថ្លែងរបស់ព្យាការីទាំង 13 ដែលបានហៅថាមាត្រានៃសេចក្តីជំនឿ ដែលបានសរសេរដោយលោកយ៉ូសែប ស្ម៊ីធ ។ វាសំខាន់ដើម្បីឱ្យយើងទន្ទេញចាំ ។ មាត្រានៃសេចក្តីជំនឿពិពណ៌នាអំពីមូលដ្ឋានជំនឿ នៃដំណឹងល្អដែលបានស្តារឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។ សេចក្តីថ្លែងទីមួយនៃសេចក្តីថ្លែងទាំងនោះអានថា: "យើងខ្ញុំជឿដល់ព្រះ គឺព្រះវរបិតាដ៏គង់នៅអស់កល្បជានិច្ច និងព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ហើយដល់ព្រះវិញ្ញាណបរិសុទ្ធ" ។2

យ៉ូសែប ស្ម៊ីធស្គាល់នូវលក្ខណៈនៃសមាជិកទាំងបីនៃក្រុមព្រះ ដោយបទពិសោធន៍ផ្ទាល់ខ្លួន។ កាលនៅក្មេង អាយុ 14 ឆ្នាំ លោកចង់ដឹងថាតើព្រះវិហារពួកគ្រីស្ទានណាមួយនៃព្រះវិហារគ្រីស្ទានទាំងឡាយ ដែលលោកគួរតែចូលរួម។ នៅក្នុងព្រះគម្ពីរប៊ីប នៅក្នុងគម្ពីរយ៉ាកុបនៃគម្ពីរសញ្ញាថ្មី លោកបានអានថាៈ "តែបើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះ ដែលទ្រង់ប្រទានដល់មនុស្សទាំងអស់ដោយសទ្ធា ឥតបន្ទោសផង នោះទ្រង់នឹងប្រទានឱ្យ"។3 ដោយការប្រណិបត្តិ លោកបានលុតជង្គង់ចុះអធិស្ឋាន ហើយត្រូវបានយាងមកជួបដោយព្រះ និងព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ។ លោកបានពិពណ៌នាថា "មានតួអង្គពីរ ដែលមានរស្មីនឹងសិរីរុងរឿងហួសអស់ទាំងការអធិប្បាយប្រាប់ បានឈរនៅលើអាកាសពីលើរូប [យ៉ូសែប] ។ តួរអង្គមួយមានព្រះបន្ទូលមកកាន់ខ្ញុំ ដោយហៅខ្ញុំតាមឈ្មោះ ហើយចង្អុលទៅម្នាក់ទៀត [ព្រះជាព្រះវរបិតា] ដោយមានព្រះបន្ទូលថា--- *"នេះជាព្រះរាជបុត្រាដ៏ជាទីស្រឡាញ់របស់យើង ចូរស្តាប់តាមទ្រង់ចុះ"*។4

ចាប់តាំងពីកុមារភាពរបស់ខ្ញុំ បទពិសោធន៍របស់លោកយ៉ូសែប ស្ម៊ីធ បានធ្វើជាការនាំផ្លូវចំពោះខ្ញុំ--- ហើយអាចធ្វើការដឹកនាំផ្លូវចំពោះយើងទាំងអស់គ្នា។ ព្យាការីវ័យក្មេងរៀនសេចក្តីពិតអំពីព្រះវរបិតាសួគ៌ និងព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ ដោយសារលោកបានស្វែងរកចង់ដឹងចេញពីបទគម្ពីរ ដែលជាព្រះទ័យរបស់ព្រះវរបិតាសួគ៌របស់លោក រួចហើយលោកបានគោរពតាមដោយស្មោះត្រង់។

គំរូនេះត្រូវបានបង្កើតឡើង និងជាគំរូដ៏ឥតខ្ចោះដោយព្រះអង្គសង្គ្រោះ តាមដែលបានកត់ត្រានៅក្នុងព្រះគម្ពីរប៊ីប។ នៅពេលព្រះយេស៊ូវ មានព្រះជន្ម 12 វស្សា មាតារបស់ទ្រង់ ម៉ារ៉ា និងឪពុកខាងសាច់ឈាមរបស់ទ្រង់ យ៉ូសែប រកឃើញទ្រង់កំពុងបង្រៀននៅក្នុងព្រះវិហារ។ ព្រះយេស៊ូវបានសួរដល់ពួកគាត់ថាៈ "តើមិនជ្រាបថាគួរឱ្យខ្ញុំនៅក្នុងព្រះវិហាររបស់ព្រះវរបិតានៃខ្ញុំទេឬអី?"5 ប៉ុន្តែព្រះយេស៊ូវមិនបានមានបន្ទូលអំពីកិច្ចការរបស់យ៉ូសែបទេ។ ទ្រង់កំពុងមានបន្ទូលអំពីកិច្ចការរបស់ព្រះវរបិតាដ៏អស់កល្បជានិច្ចនៅក្នុងឋានសួគ៌របស់ទ្រង់។

លក្ខណៈដែលព្រះជាព្រះវរបិតាបានណែនាំព្រះរាជបុត្រារបស់ទ្រង់ នៅក្នុងឱកាសជាច្រើនគឺសំខាន់ណាស់ថាៈ "កាលព្រះយេស៊ូវបានទទួលបុណ្យជ្រមុជទឹកហើយ នោះទ្រង់យាងឡើងពីទឹកភ្លាម... នោះមានឮសំឡេងចេញពីមេឃថាៈ នេះជាកូនស្ងួនភ្ងារបស់អញ ជាទីពេញចិត្តអញណាស់"។6 ហើយជាថ្មីម្តងទៀតនៅលើភ្នំផ្លាស់ប្រែ "ហើយមានសំឡេងចេញពីពពកមកថា នេះជាកូនស្ងួនភ្ងាអញ ចូរឱ្យស្តាប់តាមចុះ"។7

នៅពេលព្រះយេស៊ូវយាងមកទ្វីបអាមេរិក ទ្រង់ត្រូវបានណែនាំតាមរបៀបដូចគ្នានេះដោយព្រះវរបិតារបស់ទ្រង់ថាៈ "មើលន៏ បុត្រាដ៏ជាទីស្រឡាញ់របស់យើង ដែលយើងគាប់ចិត្តណាស់ ដែលបានដំកើងដល់នាមរបស់យើង--- ចូរស្តាប់តាមបុត្រាយើងចុះ"។8 រួចហើយនៅជិតពីសហសវត្សន៍ក្រោយមក បន្ទូលដូចគ្នានេះត្រូវបានមានបន្ទូលមកកាន់យ៉ូសែប ស្ម៊ីធវ័យក្មេងថាៈ " *នេះជាព្រះរាជបុត្រាដ៏ជាទីស្រឡាញ់របស់យើង ចូរស្តាប់តាមទ្រង់ចុះ!*"9

វាគឺអំពីសារៈសំខាន់ពិសេស នៅពេលដែលព្រះវរបិតាសួគ៌ សព្វព្រះទ័យនឹងណែនាំបុត្រារបស់ទ្រង់ចំពោះយើង ទ្រង់បញ្ជាយើងឱ្យស្តាប់តាម--- "ស្តាប់" បន្ទូលរបស់ព្រះយេស៊ូវ។

តើព្រះយេស៊ូវជានរណា? ទ្រង់បានចូលរួមជាមួយនឹងព្រះវរបិតារបស់ទ្រង់នៅក្នុងការបង្កបង្កើតពិភពលោក ហើយបានឆ្លើយតប ក្រោមការដឹកនាំរបស់ព្រះវរបិតារបស់ទ្រង់ ដើម្បីបង្កើតវត្ថុសព្វសារពើរនៅលើផ្ទៃផែនដី។ "ហើយពិភពលោកដ៏ច្រើនឥតគណនា នោះយើងបានបង្កើតឡើង ហើយយើងបានបង្កើតរបស់ទាំងនោះឡើងសំរាប់គោលបំណងរបស់យើងផ្ទាល់ ហើយដោយសារព្រះរាជបុត្រា នោះយើងបានបង្កើតរបស់ទាំងនោះមក គឺជាព្រះរាជបុត្រាបង្កើតតែមួយរបស់យើង"។10 ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រាដែលជាព្រះរាជបុត្រាបង្កើតតែមួយនៃព្រះវរបិតា។ ទ្រង់គឺជាអ្នកសង្រួបសង្រួមរបស់យើងជាមួយនឹងព្រះវរបិតា។ ទ្រង់គឺជាព្រះអង្គសង្គ្រោះ ដែលបានដាក់ជីវិតរបស់ទ្រង់ដើម្បីយើង ហើយបានជាអ្នកដែលកំពុងអង្វរជំនួសរបស់យើងជាមួយព្រះវរបិតា។ ហេតុដូច្នោះហើយ យើងអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌នៅក្នុងព្រះនាមនៃព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ។ ព្រះយេស៊ូវ ជាព្រះរាជបុត្រា មិនមែនមានតួរអង្គតែមួយជាមួយនឹងព្រះវរបិតាទ្រង់នោះទេ ប៉ុន្តែទ្រង់ *មានរូបអង្គដូចជា* ព្រះវរបិតារបស់ទ្រង់។ ទ្រង់ក៏ជាតួរអង្គដ៏រុងរឿងនៃព្រះចេស្តារ និងសិទ្ធិអំណាចផងដែរ។

វាគឺជាការត្រេកអរណាស់ ហើយជិតជាប់ក្នុងចិត្តខ្ញុំ ដើម្បីពិចារណាអំពីរបៀបដែលព្រះយេស៊ូវមានបន្ទូលទៅកាន់ព្រះវរបិតារបស់ទ្រង់។ នៅក្នុងការអធិស្ឋានអង្វរជំនួសដ៏អស្ចារ្យ ដែលបានរកឃើញនៅក្នុងព្រះគម្ពីរប៊ីបនៅក្នុងគម្ពីរយ៉ូហាន វាគឺជាភាពច្បាស់លាស់បំផុត ដែលព្រះយេស៊ូវបានប្រាប់ថាទ្រង់គឺជាបុត្រា។ សូមស្តាប់បន្ទូលរបស់ទ្រង់ នៅពេលទ្រង់រាយការណ៍អំពីបេសកកម្មលើផែនដីដែលបានបញ្ចប់ដោយការគោរពប្រណិបត្តិទៅកាន់ព្រះវរបិតាដែលគង់នៅឋានសួគ៌។

"ទូលបង្គំបានដំកើងទ្រង់នៅផែនដី ទូលបង្គំបានបង្ហើយការ ដែលទ្រង់ប្រគល់មកធ្វើ...។ ត្បិតអស់ទាំងព្រះបន្ទូលដែលទ្រង់បានប្រទានមក នោះទូលបង្គំបានឱ្យដល់គេ [ពួកសិស្ស] ហើយ... ក៏ជឿថាទ្រង់ចាត់ឱ្យទូលបង្គំមកមែន...។ ទូលបង្គំបានចាត់គេឱ្យទៅក្នុងលោកិយ ដូចជាទ្រង់ចាត់ទូលបង្គំឱ្យមកក្នុងលោកិយដែរ...។ ឯសិរីល្អដែលទ្រង់ប្រទានមកទូលបង្គំ នោះទូលបង្គំបានឱ្យដល់គេហើយ ដើម្បីឱ្យគេបានរួបគ្នាតែមួយ ដូចជាយើងក៏រួមតែមួយដែរ"។11

តាមរយៈព្រឹត្តការណ៍នៃការបំរើរបស់ព្រះអង្គសង្គ្រោះ ពួកសិស្សបានរួមគ្នាតែមួយមែន ប៉ុន្តែមិនមែនតែមួយនៅក្នុងរូបកាយពួកគេនោះទេ។ ពួកគេរួមតែមួយនៅក្នុងគោលបំណង និងសេចក្តីស្រឡាញ់។ នេះគឺជាភាពតែមួយនៃព្រះជាព្រះវរបិតា និងព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ ដែលបាននិយាយនៅក្នុងបទគម្ពីរ។ ពួកទ្រង់មានតួអង្គផ្សេងពីគ្នា ប៉ុន្តែពួកទ្រង់តែមួយនៅក្នុងគោលបំណង នៅក្នុងសេចក្តីស្រឡាញ់របស់ពួកទ្រង់ចំពោះយើង និងនៅក្នុងកិច្ចការដែលពួកទ្រង់កំពុងតែធ្វើជំនួសយើង។

ព្រះអង្គសង្គ្រោះក៏បានបន្តអធិស្ឋានផងដែរថាៈ "ឱព្រះវរបិតាអើយ សូមដំកើងទូលបង្គំ... ដោយសិរីល្អដែលទូលបង្គំមានជាមួយទ្រង់ក្នុងកាល ដែលលោកិយមិនទាន់បានកើតនៅឡើយ...។ ... ប្រយោជន៍ឱ្យលោកិយបានដឹងថាគឺទ្រង់ដែលចាត់ឱ្យទូលបង្គំមកមែន ហើយថា ទ្រង់ស្រឡាញ់គេ ដូចជាស្រឡាញ់ទូលបង្គំដែរ។ ... ត្បិតត្រង់បានស្រឡាញ់ទូលបង្គំតាំងតែពីមុនកំណើតលោកិយរៀងមក"។12 ឱ តើទ្រង់ចង់ឱ្យយើងស្គាល់ព្រះវរបិតាដូចជាទ្រង់ខ្លាំងយ៉ាងណា។ ទ្រង់បានអធិស្ឋានថាៈ

"ឱព្រះវរបិតាដ៏សុចរិតអើយ លោកិយមិនស្គាល់ទ្រង់ទេ តែទូលបង្គំស្គាល់ទ្រង់ ហើយ [សិស្ស] ទាំងនេះក៏ដឹងថា ទ្រង់បានចាត់ឱ្យទូលបង្គំមកដែរ។ ទូលបង្គំបានឱ្យគេស្គាល់ព្រះនាមទ្រង់ក៏នឹងសំដែងឱ្យគេស្គាល់តទៅទៀត ដើម្បីឱ្យសេចក្តីស្រឡាញ់ ដែលទ្រង់ស្រឡាញ់ដល់ទូលបង្គំបាននៅក្នុងគេ ហើយឱ្យទូលបង្គំនៅក្នុងគេដែរ"។13 ព្រះយេស៊ូវបានបង្ហាញសេចក្តីស្រឡាញ់ដ៏មហិមារបស់ទ្រង់ចំពោះអ្នកទាំងឡាយ ដែលជ្រើសរើសតាមទ្រង់ នៅពេលទ្រង់បានអធិស្ឋានសំរាប់ការការពាររបស់ពួកគេថា:"ទូលបង្គំមិនសូមឱ្យយកគេចេញពីលោកិយទេ គឺសូមឱ្យទ្រង់រក្សាគេឱ្យរួចពីសេចក្តីអាក្រក់វិញ"។14

រួចហើយព្រះអង្គសង្គ្រោះរបស់យើងបានសុំដោយទន់ភ្លន់ ដែលមានអត្ថន័យចំពោះយើងថា ដើម្បីឱ្យពួកគេអាចនៅជាមួយទ្រង់ម្តងទៀត:

"ឱព្រះវរបិតាអើយ ឯពួកអ្នកដែលទ្រង់ប្រទានមកទូលបង្គំ នោះទូលបង្គំចង់ឱ្យគេនៅជាមួយនឹងទូលបង្គំក្នុងកន្លែងដែលទូលបង្គំនៅដែរ"។15

នៅក្នុងការរៀបចំសំរាប់ពិលិកម្មដង្វាយធួន ព្រះយេស៊ូវបានអធិស្ឋានទៅកាន់ព្រះវរបិតារបស់ទ្រង់ នៅក្នុងសួនច្បារគេតសេម៉ានី នៅពេលទ្រង់យកមកដាក់លើខ្លួនទ្រង់នូវអំពើបាប ទុក្ខព្រួយ និងការឈឺចាប់របស់មនុស្សគ្រប់រូប។ នៅក្នុងម៉ោងទាំងនោះ ទ្រង់នៅតែឯង បានបង្ហាញយ៉ាងច្បាស់លាស់ថា ទ្រង់មិនមែនកំពុងតែធ្វើកិច្ចការផ្ទាល់ខ្លួនរបស់ទ្រង់ទេ។ ទ្រង់បានអធិស្ឋានថា "ឱព្រះវរបិតានៃទូលបង្គំអើយ បើសិនជាបាន នោះសូមឱ្យពែងនេះកន្លងហួសពីទូលបង្គំទៅ ប៉ុន្តែកុំតាមចិត្តទូលបង្គំឡើយ សូមតាមតែព្រះហឫទ័យទ្រង់វិញ"។16 នៅក្នុងពេលដ៏សំខាន់បំផុតនេះចំពោះទ្រង់ និងចំពោះយើងទាំងអស់គ្នា ទ្រង់មិនមែនកំពុងតែមានបន្ទូលមកកាន់ខ្លួនទ្រង់ ឬពឹងផ្អែកទៅលើកម្លាំងផ្ទាល់របស់ទ្រង់នោះទេ។ ទ្រង់ទូលទៅព្រះវរបិតា ព្រះដ៏មានព្រះចេស្តារលើទាំងអស់ ដើម្បីគាំទ្រដល់ទ្រង់ និងអនុញ្ញាតឱ្យទ្រង់ធ្វើតាមព្រះហឫទ័យរបស់ព្រះវរបិតារបស់ទ្រង់ ហើយព្រះវរបិតារបស់ទ្រង់បានបញ្ជូនទេវតាមួយអង្គ "មកពីឋានសួគ៌មកចំរើនកម្លាំងរបស់ទ្រង់"។17 ខ្ញុំពេញចិត្តណាស់នឹងក្តីស្រឡាញ់ដែលព្រះវរបិតាបានមានចំពោះព្រះរាជបុត្រារបស់ទ្រង់ និងចំពោះយើងទាំងអស់គ្នា។

តាំងពីមុនកំណើតលោកិយមករហូតមកដល់ខណៈពេលចុងក្រោយនៅលើឈើឆ្កាង ព្រះអង្គសង្គ្រោះធ្វើនូវកិច្ចការរបស់ព្រះវរបិតារបស់ទ្រង់។ ទ្រង់បានបំពេញកិច្ចការ ដែលទ្រង់បានបញ្ជូនឱ្យមកធ្វើ។ ហេតុដូច្នេះហើយ យើងមិនចាំបាច់ងឿងឆ្ងល់ថា តើទ្រង់មានបន្ទូលទៅកាន់នរណា នៅពេលនៅលើឈើឆ្កាងនោះទេ "ទ្រង់បានមានបន្ទូលថាការស្រេចហើយ"18 ហើយ "ហើយស្រែកឡើងជាខ្លាំងថា... ឱព្រះវរបិតាអើយ ទូលបង្គំសូមប្រគល់វិញ្ញាណដល់ព្រះហស្តទ្រង់វិញ កាលមានបន្ទូលពាក្យទាំងនេះរួចហើយ នោះទ្រង់ផុតដង្ហើមទៅ"19 យើងដឹងថាទ្រង់កំពុងតែអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌របស់ទ្រង់។

ខ្ញុំធ្វើទីបន្ទាល់ថាព្រះអង្គសង្គ្រោះមានព្រះជន្មរស់។ ទ្រង់គឺជាបុត្រជាទីស្រឡាញ់តែមួយគត់របស់ព្រះវរបិតា ហើយទ្រង់នឹងយាងមកម្តងទៀតនៅលើផែនដីនេះដើម្បីសោយរាជ្យ។ ទ្រង់គឺជាព្រះយេស៊ូវគ្រីស្ទ ជាព្រះដ៏បរិសុទ្ធនៃអ៊ីស្រាអែល "ពោរពេញទៅដោយព្រះគុណ និងសេចក្តីមេត្តាករុណា និងសេចក្តីពិត...។ ហើយមើលចុះគឺព្រះអង្គនេះហើយដែលនឹងយាងមក ដើម្បីយកអំពើបាបទាំងឡាយនៃមនុស្សលោក មែនហើយគឺអំពើបាបទាំងឡាយនៃមនុស្ស

គ្រប់គ្នា ដែលជឿយ៉ាងខ្ជាប់ខ្ជួនដល់ព្រះនាមរបស់ទ្រង់" ។20 ទ្រង់គឺពិតជាព្រះរាជបុត្រារបស់ព្រះ ដែលបានរស់ឡើងវិញពីសេចក្តីស្លាប់ នៅថ្ងៃទីបី បាននាំមកនូវការរស់ឡើងវិញដ៏ពិតចំពោះមនុស្សគ្រប់រូប ដែលនឹងមកលើផែនដីនេះ។ ខ្ញុំក៏ថ្លែងទីបន្ទាល់ផងដែរថា ព្រះជាព្រះវរបិតាសួគ៌ដ៏អស់កល្បជានិច្ចរបស់យើងមានព្រះជន្មរស់ ហើយស្រឡាញ់យើងម្នាក់ៗ ព្រោះយើងគឺជាកូនចៅរបស់ទ្រង់។ សេចក្តីស្រឡាញ់របស់ទ្រង់គឺមហិមាណាស់ ដែលទ្រង់បានបញ្ជូនព្រះរាជបុត្រាជាទីស្រឡាញ់តែមួយមកក្នុងពិភពលោក ដើម្បី "ឱ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឱ្យមានជីវិតអស់កល្បជានិច្ចវិញ" ។21

ក្នុងនាមជាសាវកមួយរូបរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ខ្ញុំសូមថ្លែងទីបន្ទាល់អំពីសេចក្តីពិត នៃអ្វីដែលមាននៅក្នុងបទគម្ពីរ និងអ្វីដែលបានប្រាប់មកកាន់ខ្ញុំ ហើយអាចត្រូវបានប្រាប់ទៅកាន់អ្នករាល់គ្នា ដោយព្រះវិញ្ញាណបរិសុទ្ធ។ វានឹងបើកសម្តែងស្របទៅតាមការគោរពប្រណិបត្តិ និងបំណងប្រាថ្នារបស់អ្នក។ ព្រះអង្គសង្គ្រោះបានបង្រៀនដល់យើងអំឡុងពេលការបំរើនៅក្នុងជីវិតរមែងស្លាប់របស់ទ្រង់ អំពីសេចក្តីពិតដ៏មហិមានេះ ដែលអនុវត្តចំពោះយើងទាំងអស់គ្នាថា: "ហើយសូម្បីជាអ្វីដែលអ្នករាល់គ្នាសុំព្រះវរបិតាដោយនូវនាមយើងដែលត្រឹមត្រូវ និងដោយជឿថាអ្នកនឹងបានទទួល មើលចុះនឹងបានប្រទានដល់អ្នក" ។22 ខ្ញុំថ្លែងទីបន្ទាល់ថា ខ្ញុំដឹងរឿងទាំងនេះ ហើយខ្ញុំដឹងដោយភាពពិត ហើយរឿងទាំងនេះដែលខ្ញុំខ្ញុំបាននិយាយគឺជាការពិត។ ដើម្បីអ្នកអាចស្វែងរកឃើញនូវភាពពិតប្រាកដដូចគ្នានេះ គឺជាការអធិស្ឋានរបស់ខ្ញុំនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. នីហ្វៃទី 3 11:32 ។

2. មាត្រានៃសេចក្តីជំនឿ 1:1 ។

3. យ៉ាកុប 1:5 ។

4. យ៉ូសែប ស៊្មីធ---ប្រវត្តិ 1:17 ។

5. លូកា 2:49 ។

6. ម៉ាថាយ 3:16--17 ។

7. លូកា 9:35 ។

8. នីហ្វៃទី 3 11:7 ។

9. យ៉ូសែប ស៊្មីធ---ប្រវត្តិ 1:17 ។

10. ម៉ូសេ 1:33 ។

11. យ៉ូហាន 17:4, 8, 18, 22 ។

12. យ៉ូហាន 17:5, 23--24 ។

13. យ៉ូហាន 17:25--26 ។

14. យ៉ូហាន 17:15 ។

15. យ៉ូហាន 17:24 ។

16. ម៉ាថាយ 26:39 ។

17. លូកា 22:43 ។

18. យ៉ូហាន 19:30 ។

19. លូកា 23:46 ។

20. អាលម៉ា 5:48 ។

21. យ៉ូហាន 3:16 ។

22. នីហ្វៃទី 3 18:20 ។